ASEAN PARLIAMENTARIANS FOR HUMAN RIGHTS

APHR

# សេចក្តីថ្លែងការណ៍

អំពើឃាតកម្មលើលោកបណ្ឌិត **កែម ឡី** អ្នកវិភាគនយោបាយដ៏សំខាន់មួយរូប គឺជាសោកនាដកម្មដ៏រន្ធត់មួយសម្រាប់ប្រទេសកម្ពុជា ក៏ដូចជាតំបន់អាស៊ានទាំងមូលផងដែរ។ ការបាត់បង់រូបលោក គឺពិតជារឿងដ៏សង្វេគ។ លោកបណ្ឌិត **កែម ឡី** ជាបុគ្គលដើម្បីគណនីភាព និងប្រជាធិបតេយ្យមូលដ្ឋាន ហើយលោកមិនខ្លាចនឹងងើបតវ៉ា ដើម្បីការពារអ្វីដែលជាភាពត្រឹមត្រូវ។ ប្រទេសកម្ពុជាបានបាត់បង់នូវវីរជននៃភាពឯករាជ្យនយោបាយ និងរដ្ឋាភិបាលស្អាតស្អំ ដ៏ពិតប្រាកដមួយរូប។

បរិយាកាសជុំវិញការបាត់បង់ជីវិតរបស់លោកបណ្ឌិត **កែម ឡី** បានបន្សល់នូវការស្រាវជ្រាវរកចម្លើយ និងមន្ទិលសង្ស័យជាច្រើន អំពីហេតុផលសម្ងាត់នៃអំពើឃាតកម្មនេះ ជាពិសេសដោយសារការនិយាយរិះគន់របស់លោកបណ្ឌិត **កែម ឡី** ចំពោះអ្នកដឹកនាំនយោបាយកម្ពុជាកន្លងមក។ រាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវជម្រុញឲ្យមានការស៊ើបអង្កេតបន្ទាន់មួយប្រកបដោយឯករាជ្យ ចំពោះអំពើឃាតកម្មដ៏សាហាវព្រៃផ្សៃនេះ ដែលនឹងធានាបាននូវយុត្តិធម៌ពិតប្រាកដ និងមិនលម្អៀង។ បើធ្វើការពិនិត្យលើបរិបទថ្មីៗនេះ ពាក់ព័ន្ធនឹងការឃាយីដោយគ្មានមូលហេតុច្បាស់លាស់លើគណបក្សជំទាស់ និងសង្គមស៊ីវិល គឺមានតែការស៊ើបអង្កេតដែលមានលក្ខណៈឯករាជ្យពិតប្រាកដចំពោះករណីឃាតកម្មនេះប៉ុណ្ណោះ ដែលនឹងអាចលុបបំបាត់នូវមន្ទិលសង្ស័យ និងអាចបន្ធូរបន្ថយភាពតានតឹង ព្រមទាំងលើកកម្ពស់នីតិរដ្ឋ និងបញ្ចប់និទណ្ឌភាពនៅកម្ពុជា។

អាជ្ញាធរកម្ពុជាត្រូវអនុញ្ញាតឲ្យប្រជាពលរដ្ឋគ្រប់រូបអាចបញ្ចេញមតិយោបល់ ក្នុងបរិយាកាសមួយប្រកបដោយសន្តិសុខ និងសុវត្ថិភាពល្អ។ រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវធានាឲ្យបាននូវការប្តេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការការពារ និងលើកស្ទួយសិទ្ធិមនុស្ស ដោយអនុលោមតាមសេចក្តីប្រកាសរបស់សហគមន៍អាស៊ាន និងសន្ធិសញ្ញាអន្តរជាតិដទៃផ្សេងទៀត ស្តីពីសិទ្ធិមនុស្ស។ ប្រសិនបើប្រទេសកម្ពុជាអាចអភិវឌ្ឍខ្លួនក្លាយជាសមាជិកដ៏ជោគជ័យមួយនៃសហគមន៍អាស៊ាន អ្នកដែលតស៊ូទាមទារឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ដែលជាបុព្វហេតុនៃការបូជាជីវិតរបស់លោកបណ្ឌិត **កែម ឡី** ច្បាស់ជាមានសេរីភាពពេញលេញក្នុងការបន្តបំពេញការងារ ដោយគ្មានភាពភ័យខ្លាចដោយការបំភិតបំភ័យ ឬទណ្ឌកម្មហិង្សានោះឡើយ។



ឯកឧត្តម Charles Santiago ( សមាជិកសភា នៃប្រទេសម៉ាឡេស៊ី )
ប្រធានអង្គការសមាជិកសភាអាស៊ាន ដើម្បីការពារសិទ្ធិមនុស្ស
ក្នុងនាមសមាជិកនៃអង្គការសមាជិកសភាអាស៊ាន ដើម្បីការពារសិទ្ធិមនុស្ស